Khmer Story Lovers

--ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៨៩ ជីឡូត៍លេខ ២៩៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ --

# ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គឹមសាន

តម្លៃ ៣០៛

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៤៤

ពោលចប់ ម្ចាស់កោះទាំងពីរប្រាណលូកដៃស្ដាំកាន់ដាវបបរ ដៃស្ដាំចាប់ចង្កឹះអញ្ចើញភ្ញៀវ ៗ អ្នកក្លាហានពល់រូប មិនដែលស្គាល់ សៅផ្ដាច់ពោះវៀនរំលាយផ្ទឹនទេ, ប៉ុន្តែពួកឈ្មោះក៏ព្រឺក្បាលសំពោងទៅហើយ ។ ពោះដឹងមុនថាខ្លួនជៀសមិនរួចពីស្លាប់ក៏មិនអាចទប់ទល់នឹងការភ័យរន្ធត់ដែរ ទម្រាំបើម្ចាស់កោះរៀបរាប់ប្រាប់គ្រឿងផ្សំហូរហែច្បាស់ណាស់ ស្ដាប់ទៅគួរឲ្យស្ញើបមែន ।

លោកតាឡុង-និង មុ កាន់ចង្កឹះព្រមទាំងលើកចានឡើងចាប់កាយបបរញាក់មាត់ធ្វើហ៊ី ។ ភ្ញៀវភាគច្រើននឹកគិតថា:

- បបរឯងពីរចាននោះពិតជាមានថ្នាំលើកកម្លាំង ជំនួសជាតិពិសហើយ ।

ខណ:នោះស្រាប់តែមានជនម្នាក់អង្គុយគុខាងកើតក្រោកឈរបង្កុលមុខម្ចាស់កោះស្រែកខ្លាំងៗ :

-នៃ ! សូមលោកគ្រូកូលឡុង និង មុ ស្ដាប់ឲ្យច្បាស់ ។ យើងឈ្មោះចេវុនផាវនៅស្រុកគួនស៊ី ។ មុននឹងមកកាន់កោះឡុងមុនេះយើងបានផ្ដុកផ្ដាក់កិច្ចការគ្រួសារអស់ហើយ ។ យើងជាកូនប្រុសឈរលើដី ក្បាលទល់មេឃ . បើពួកឯងចង់សម្លាប់យើងមិនព្រាកេមទេ, បើឯងបង្ខំយើងឲ្យស៊ីពិសពុលកខ្វក់បែបនេះ

- យើងមិនលេបផាផាចខាត ។

ម្ចាស់កោះឡុងមុមិងមាំងបន្តិចទើបសើចៈ

-បើអ្នកក្លាហានក្រគូល បេ មិនចូលចិត្តពិសាបបរនេះទេ, យើងក៏មិនហ៊ានបង្ខំដែរ, ម៉េចចាំបា
ខឹងសម្បារ ? អញ្ជើញអង្គុយចុះមក ។

ចេរ៉ុនផាវស្រែកសន្ធាប់ៈ

- យើងបានប្រគល់ជីវិតឲ្យពួកឯងស្រេចហើយតើ, ស្លាប់ពេលណាក៏បានដែរ, ប៉ុន្តែជាតិជាកូន
ប្រុសយើងត្រូវតែប្រឆាំងនឹងពួកបិសាចដែលប្រព្រឹត្តអំពើឧក្រិដ្ឋបំផ្លិចបំផ្លាញអនាគត និងសេចក្តីសុខរបស់
គេហ៊ុនឯងនេះសិន ។

ពោលចប់ គាត់លើកចានបបរក្តៅគគុកគ្រវែងលើមុខតាឡុងម្ចាស់កោះ, តែភ្លាមនោះមានតាចាស់
ម្នាក់ដែលអង្គុយក្បែរមុខចេរ៉ុនផាវក្រោកឈរវៃគូតស្រែកឃាត់ :

— សុំលោក បងចេរ៉ុផាលប្រឡាតពេក!

ពោលផងគាត់រលាស់ដៃតាវផង បញ្ចេញខ្យល់ដៃឃាត់ចានបបរក្នុងលំហអាកាស ។ ចានបប
ហើរសន្សឹមៗ ហៀបធ្លាក់ដល់ដីកំពប់បបរខ្ចាត់ខ្ចាយទៅហើយ ស្រាប់តែមានបំរើម្នាក់ស្ទុះមកទ្រ
ចានបបរជាប់ សល់តែមួយហត្ថទៀត, ចានក៏បែកបបរក៏កំពប់អស់មិនខាន ។

ជនទាំងអស់ស្រែកហ៊ោថាៈ អស្ចារ្យមែន !

សុរិម្រុកហ៊ោស្ងប់ស្ងាត់ទៅ, ភ្ញៀវទាំងអស់រិតតែលំបាកចិត្តឡើងៗ ព្រោះឃើញច្បាស់នឹង
ភ្នែកថាសូម្បីបំរើតូចតាចក៏ពូកែដែរ, តើពួកយើងអាចរត់គេចផុតពីទីនេះឬទេ ?

គេមានមុខស្រពាប់ស្រពោនគ្រប់គ្នាក៏យន្ធត់លើសដើម ។ ខ្លះនឹកដល់កូនចៅ,ទ្រព្យសម្បត្តិ,
ដីភូមិ, ខ្លះនឹកស្តាយបំណុលឈាមដែលមិនទាន់បានសងសឹក, ខ្លះនឹកដល់កិច្ចការក្នុងក្រុមបក្សដែលត្រូ
រលាយសាបសូន្យ, ខ្លះទៀតបន្ទោសតែខ្លួនឯងថា បើដឹងពេលវេលាសេនាបញ្ញាមរណៈចេញមុខដើរើក
ផ្កាកស្លាន់ហើយ ម្តេចមិនរត់រកកន្លែងជ្រកពួនមួយគ្រាសិន ? ម្តេចក៏ទៅរុញក្រញាញលើកៅអីតាយ
ក្រុមឧត្តុលខុសត្រូវជំនួសគេ ? នៅស្មានថាកោះឡុងមុនិងបបរខែកត្តិកជាពាក្យបំបាមភេរម ?

ឥឡូវគេឃើញរូបពងកោះឡុងមុ ឃើញចាំងម្ចាស់កោះ ឃើញចាំងសេនាតូចធំ, គ្រាន់តែអ្នកបំរើ
ចាក់ស្រាលើកម្ទូបក៏ពូកែដែរ ។ តែប៉ុណ្ណោះហើយសេចក្តីសង្ឃឹមតូចតាចជាចុងក្រោយត្រូវរលាយ

ទើបបានជួបលោកក្នុងថ្ងៃនេះ ហើយខ្ញុំមិនហ៊ានធ្វើអ្វីឲ្យខុសចិត្តលោកទេ ។

ស៊ីមិនពុឈើនតបភ្លាម:

— បាទអរគុណ ។ រឿងខ្ញុំកួចកំប៉ិកកំប៉ុកប្រហែលអាចធ្វើឲ្យពិភពគុនផ្នែកដីគោកភ្ញាក់ផ្អើលខ្លះមែន, តែចំពោះម្ចាស់កោះឡុងមុប្រហែលមិនល្បីដល់ត្រចៀកលោកកាំបិតដើរទេ ។

តាចាស់ត្រកូលឡុងប្រញាក់ :

— សូមលោកគ្រូស៊ីមិនកុំបន្ទាបខ្លួនពេក, បន្តិចទៀតគង់ខ្ញុំនាំបងឲ្យអស់សង្ស័យមិនខាន ។ ប៉ុន្តែសុំប្រាប់ថាបបរស្មៅផ្កាចំពោះរឿងរំលាយថ្នាំនេះបើពិសាទាំងក្ដៅឃើញថាមានប្រយោជន៍ច្រើន, ហេតុនេះសូមអញ្ជើញអស់លោកពិសាប្រូសិន, សឹមខ្ញុំពន្យល់ឲ្យអស់ក្ដីសង្ស័យ ។

ស៊ីផានមិនសូវចេះស្ដាប់ពាក្យពេចន៍ទាំងនេះទេ, នាយកំពុងក្ដូរពោះគ្រូកគ្រាក់ឃ្លានដល់កំរិតហើយ ។ កាលឃើញម្ចាស់ផ្ទះអញ្ជើញដូច្នេះនាយលើកចានបបរហុតគ្រូក ៗ អស់កន្លះចានភ្លាម ។ បបរនេះក្ដៅគគុកខ្លាំងមែន តែមានរសជាតិផ្អែមឆ្ងាញ់ណាស់, មួយពព្រិចភ្នែកក្រោយនាយហូបអស់រលីង ។

អ្នកក្លាហានឯទៀតឃើញបុគ្គលាមាណព ក៏ក្ដៅខឹងថា :

— អាក្មេងនេះរពឹសមែន ! ឥតស្គាល់ស្លាប់តែម្ដង ... វាចង់អួតអាងថាមិនខ្លាចស្លាប់ឬ ? ទោះបីថាចៀសមិនផុតក៏មិនត្រូវផ្ដើមចូលទៅរកគ្រោះមុនគេរបៀបនេះដែរ ។

អ្នកខ្លះគិតថាបើគង់តែស្លាប់ដែលគួរស្លាប់ឲ្យរកសប្បុរសក្មេងស្រស់នេះទើបសម ។

រីប៉ាយដឹកាយសប្បាយចិត្តណាស់ទះដៃស្រែកហ៊ោម្នាក់ឯងថា :

— អស្ចារ្យណាស់ ! ទៅប្រសានាយក្រុបក្អឹកកកក្លាហានលើសគេ !

ពេលនេះគាត់យល់ស៊ប់ជាងមុនថា ក្នុងលោកនេះក្រុមបក្សមួយណាក៏ចាញ់ប្រៀបក្រុមភ្នំទឹកកកមួយកំរិតដែរ ។ តាចាស់យល់ម៉្យាងទៀតថា ស៊ីផានអនាគតទៅប្រសាលើកមុខលើកមាត់គាត់សម្បើមណាស់ ។

* *

*

## វគ្គទី ៤០

## អាថិកំបាំងលើកោះឡុងមុ

កាលប្រយុទ្ធគ្នាក្នុងទីឃុំឃាំងលើគ្គីកកកនោះ ស៊ីផានធ្វើឲ្យប៉ាយជីចាយ ប៉ាក់ស្បាតម្តងហើយ ។ គាត់នឹកថា: ។

- យើងលើកខ្លួនជាជើងឯកខាងកម្លាំងធាតុ , អាវុធសម្ងាត់ប្អូនជាវ ... ត្រូវលប់ចោលផ្នែកកម្លាំងធាតុមួយសិន ។

ថ្ងៃនេះមកដល់កោះឡុងមុ ឃើញអ្នកបំរើហក់ចេញទៅទ្រចានបបរ គាត់យល់ថា ធ្វើជើងឯកមិនស្រួលកើតទេ ដោយនឹកទៀតថា:

- ពួកនៅកោះឡុងមុមិនមែនខ្លាំងពូកែដូច ៗ គ្នាទេ, ច្បាស់ជាគេឲ្យអ្នកខ្លាំងពូកែធ្វើជាបំរើដើម្បីបំភ័យយើងហើយ ។

ឥឡូវឃើញស៊ីផានលើកចានបបរហុតមុនគេ, ប៉ាយជីចាយរីករាយណាស់ ដោយមានចៅប្រុសអង់អាចក្លាហានលើសអ្នកដទៃ ។ គាត់ស្រស់សប្បាយស្ទើរស្លាប់ ប្រញាប់លើកចានបបរហុតក្រេក ១ បណ្តើរនឹកក្នុងចិត្តបណ្តើរ:

- នៅក្នុងបន្ទប់ដ៏ធំទូលាយនេះ មានតែជីតានិងចៅពីរនាក់នេះទេដែលហ៊ានហុតបបរមុនគេ ។ ម៉េច ក្រៅពីនេះ, នរណាហ៊ានទៀត ? អើហ្ន៎ ! យើងហុតបបរក្រោយគេ ត្រូវចាត់ទុកជាអ្នកក្លាហានលេខពីរ, ដូច្នេះពាក្យមុនដែលថា ជើងឯកត្រូវលប់ចោលទៀតហើយ !

គាត់ស្រស់នឹកសព្វគ្រប់តែឡប់ស្មារតីចង់ទិងខ្លួនឯង , បន្ទោសខ្លួនឯងថា:

- បើគង់តែស្លាប់ដោយសារបបរនេះដដែល , ម៉េចយើងមិនហុតមុនគេយកលេខមួយ ? ឥឡូវធ្លាក់ដល់លេខពីរ គួរឈឺចិត្តណាស់ ។

គាប៉ាយវិលបណ្តែតអារម្មណ៍រវើរវាយទៅឆ្ងាយ ឥតស្តាប់ឮតាក្រកូលឡុងពន្យល់គេទេ ។

ម្ចាស់កោះក្រកូលឡុងពោល:

-កាលពីសែសិបឆ្នាំមុន, ខ្ញុំបាទនិងប្អូនមុ ស្រុះស្រួលមូលចិត្តគ្នាពិគ្រោះក្បួនយុទ្ធសិល្បៈមួយចប់ ហើយយើងស៊ើបសរសើរគ្នាទៅវិញទៅមក បបួលគ្នាទៅសាកផលក្នុងពិភពគុនដូចអ្នកក្លាហានឯទៀត ។ ប៉ុន្តែយើងមិននឹកស្មានថា នៅពេលចេញដំណើរផ្សងព្រេងដំបូង បានប្រទះឃើញផែនទីមួយសន្លឹកដោយ

បែងខ្សែសោះ ៗ យើងមើលអក្សរល្អិតៗ លើផែនទីឃើញច្បាស់ថាចំណុចខ្មៅលើក្រដាសជា កោះមួយដាច់សង្វែងគ្មានឈ្មោះ តែជាប្រភពភាពចំប៉ាំងនៃយុទ្ធសិល្បៈកំពូល ...

បេរុនផាវស្រែកកាត់ :

- ជាកោះឡុងមុះហើយ, ម៉េចក៏ថាគ្មានឈ្មោះ ?

តាចាស់ដែលបានបក់ខ្យល់ឃាត់ចានបាយអន្ទ្រុយកៀរគាត់នោះបានឃាត់តិច ៗ :

- ប្អូនផាវកុំកាត់ប្រសាសន៍លោកម្ចាស់កោះ ៗ

បេរុនផាវពោលដោយកំហឹង :

- យីអើ ! ទោះលោកបងផ្តាច់ផ្លូនគេយ៉ាងណាក៏មិនរួចជីវិតដែរ កុំប្រឡូំ !

តាចាស់ខឹងក្រហមមុខ លើកចានបាយខែកគ្គិកហុតគ្រូកអស់កន្ទះចានភ្លាមព្រមទាំងពោល :

- យើងរកមានស្រឡាញ់គ្នាជាបងប្អូនច្រើនឆ្នាំមកហើយ, ប្អូនផាវចាត់ជីងគួងជីយើងនេះជា មនុស្សប្រភេទណា ?

បេរុនផាវកើតការស្តាយក្រោយមួយរំពេចលន់តួថា :

- លោកបង, ខ្ញុំខុសហើយ សូមលោកបងអភ័យទោស !

ពោលចប់គាត់លុតជង្គង់សំពះតាចាស់ឈ្មោះជីងគួងជីបីដងទាល់តែប៉ះក្បាលនឹងថ្មក្បឺប ១...បន្ទាប់ ពីនោះក្រោកឈរកញ្ឆក់ចានបាយលើកហុតគ្រូក !

តាចាស់ឈ្មោះជីងគួងជីស្ទុះក្វែតទៅឱបគាត់ជាប់ :

- ប្អូនប្រុសអើយ ! យើងសុំគ្នាជាបងប្អូន, បានស្បថស្បែស្លាប់រស់ជាមួយគ្នា ទោះមិនមែនកើតក្នុង ថ្ងៃតែមួយក៏ដោយ ៗ ឥឡូវបានស្លាប់ទាំងអស់គ្នាដោយសារបាយនេះហើយ !

អ្នកទាំងពីរឱបរិតគ្នាសប្បាយផងកំសត់កម្រផងហូតហូរទឹកភ្នែករៀងខ្លួន ៗ

ស៊ីផានឃើញការផ្លានខ្វាចផ្សាបែបនេះក៏ងាកទៅមើលបាងសានទិងលីសៃ ៗ ក្នុងពេលជា មួយនោះបាងសានទិងលីសៃពោលភ្នែកមើលម្ចាស់កោះឡុងមុះយោបល់ ៗ តាចាស់ទាំងពីរ ងក់ក្បាលបន្តិច, បាងសានទិងលីសៃដើរចេញមកកាន់បាយម្នាក់មួយចានតម្រង់ស៊ីផានព្រមទាំងពោល:

- សូមប្អូនប្រុសអញ្ជើញ !

មាណពកដែប្រកែកភ្លាម :

-ទេ...លោកបងទាំងពីរមិនត្រូវស្លាប់ជាមួយខ្ញុំឡើយ ខ្ញុំសុំផ្តាំតែប៉ុណ្ណឹង សូមបងឧស្សាហ៍ទៅលេងនឹងអាស៊ីវផង...

ហង់សានពោលគាត់ទាំងញញឹម :

-ប្អូនប្រុសភ្លេចអស់ហើយឬ ? កាលយើងសុំគ្នាជាបងប្អូនយើងបាននិយាយថាម៉េចខ្លះ? យើងសច្ចាថារួមសុខទុក្ខជាមួយគ្នាដែរណា ! ម៉្លោះហើយបើប្អូនហុតបបរ, បងទាំងពីរមិនអាចនៅស្ងៀម ឱបដៃមើលឡើយ ។

ពោលចប់សេនាបញ្ជាមរណៈទាំងពីររូបលើកចានបបរហុតគ្រឹក ៗ អស់រលីងទើបងាកទៅគោរពម្ចាស់គេះពោលថា :

- អរគុណលោកគ្រូណាស់ ។

រួចហើយគេត្រឡប់ទៅកាន់កន្លែងដើមវិញ ។ អ្នកក្លាហានគ្រប់គ្នាឃើញហង់សាននិងសីសែបំពេញកិច្ចសន្យាជាបងប្អូនធម៌ដោយកាយវិការពិបាកលើសករណីចេវ៉ុនផាវ និង ជីងគួងជី គេស្ងើចសរសើរណាស់ ៗ

ចាំយសឺចាយនឹកថា :

-ពីរនាក់នេះមិនត្រូវស៊ីបបរសោះ, គេសុខចិត្តសុំត្រូវស៊ីតាមកាច្រមក់ចៅប្រសាយើងដើម្បីស្លាប់ជាមួយវា ។ នេះបានហៅថាអ្នកក្លាហានត្រឹមត្រូវសមមានឈ្មោះថាវីរបុរស ។ ចំពោះយើងវិញបើប្អូនធម៌យើងផឹកថ្នាំពុល, តើយើងសុខចិត្តផឹកតាមគេដែរ ?

ខណៈនោះពុហង់សានងាកមកបញ្ជាក់ប្រាប់ស៊ីផពាន :

-អ៊ីប្អូនប្រុស, អស់លោកជាភ្ញៀវដូចជាមិនចូលចិត្តពិសាបបរនេះទេ, បើប្អូនមិនទាន់ឆ្អែតប្អូនអាចហូបទៀតបាន ។

មាណពហុតបបរមួយចានមិនទាន់ឆ្អែតមែន, កាលបើពុហង់សានបើកដៃឲ្យហូបថែមនាយយល់ថាគង់តែស្លាប់ដដែល, ទោះហុតថែមពីរបីចានទៀតក៏គ្មានទាស់ខុសដែរ, ម៉្លោះហើយនាយងាកមើលអ្នកស្គាំសម្ពឹងចានបបរក្បែរៗខ្លួន ។ ភ្ញៀវទាំងឡាយដែលផ្គុយជិតនោះបបួលគ្នាហុចបបរខ្លួនឲ្យមាណពព្រមទាំងពោល:

-បបរនេះក្លិនឆ្ងុយណាស់, ខ្ញុំបាទមិនធ្លាប់ភ្លក្សទេ បើលោកប្រុសត្រូវការសូមអញ្ជើញដោយសេរី,

មិនបាច់គួរសមទេ ។

គេខ្លាចស៊ីផានចិត្តលបបរមិនទាន់ ហើយខ្លាចតាន់សានកែប្រពាក្យសំដីក្ដីមិនលើកតានរៀនខ្ល
ដាក់លើកុមារណាពក្លាមៗ ។ ស៊ីផានងក់ក្បាលតប:

-សូមអរគុណអស់លោកច្រើនណាស់ ។

នាយលើកបបរហុតគ្រូកៗអស់ពីរគោមមួយរំពេច ។ តាម្ចាស់កោះឡុងមុងក់ក្បាលពោល
ទាំងញញឹម:

-លោកប្អូនខាងណោះមានប្រសាសន៍ត្រូវណាស់ ។ កោះផត ឈ្មោះដែលមានចំណុចពេ
ដែនដីនោះគឺកោះឡុងមុសពាថៃនេះឯង ។ ប៉ុន្តែនេះជាឈ្មោះបងប្អូនយើងខ្ញុំទេ, សូមអស់លោ
អភ័យទោស ។

កាលណាតែនាក់បងប្អូនខ្ញុំដើរកត់ក្បាតលើកោះតាមតំបន់ផែនដី អស់រយៈពេលជាងកន្លះវ៉ៃចេ
រកឃើញកន្ទួនណាក់គម្ពីរយុទ្ធសិល្បៈ ចម្លែក ។ គម្ពីរនោះជាសេចក្ដីចម្លងកំណាព្យប៉ុកណាមួយ
ប្បាប់មានន័យស្មុគស្មាញហើយជ្រៅជ្រះណាស់ ។ យើងត្រេកអរក្រៃលែងចាប់ផ្ដើមហាត់រៀ
តាមទ្រឹស្ដីនោះភ្លាម, ប៉ុន្តែហ៊ឹ ! ... យើងហាត់រៀនតាមប៉ុន្មានឆ្នាំស្រាប់តែយើងដឹងថាយល់ផ្ទុយពីគ្ន
ស្រឡះគឺខ្ញុំហាត់រៀនមួយបែប, ប្អូនមុហាត់រៀនមួយបែបផ្សេង ។ យើងជជែកគ្នាច្រើនថ្ងៃ
នៅតែមិនចុះសម្រុងគ្នាដដែល ។

លុះជជែកចុះជជែកឡើង, យើងសម្រេចចិត្តថាហាត់រៀនតាមការយល់រៀងខ្លួនបន្តទៅទៀតសិន,
កាលណាចេះចប់យើងសាកល្បងថ្វីដៃគ្នាមើល នរណាចាញ់អ្នកនោះហាត់ខុសហើយ ។

យើងទំហាត់រៀនរៀងខ្លួនឥតហានធ្វេសប្រហែសអស់ពេលកន្លះឆ្នាំទើបសាកល្បងថ្វីដៃ ។ ទើ
នឹងប្រកួតគ្នាប៉ុន្មានលើកៀតស្រាប់តែយើងភ័យខ្ទត់ថែកញើសស្រាក់រៀងខ្លួនព្រោះ ... ព្រោះ ...

ពោលដល់នេះម្ចាស់កោះឡុងមុធ្វើមុខស្រងូតឈប់ស្ងៀមមួយស្របក់ទើបបន្ត:

-ព្រោះយើងហាត់ហ្វឹកហ្វឺនខុសរបៀបដូចគ្នា !

ភ្លៀវតាំងអស់ព្រឺក្បាលខ្លាក នឹកថាបើយោលលើកំរិតយុទ្ធសិល្បៈមនុស្សប៉ុនេះជាសិស្សគណា, ម្ចាស
កោះឡុងមុពិតជាហាត់រៀនយុទ្ធសិល្បៈផ្នែកកម្លាំងកាយហើយ, បើរៀនខុសរបៀបមែនគេត្រូវធ្លាក់គ្រោះពី
សណ្ឋាន, ឬមួយរបួសគ្រាំគ្រាហូតពិការឬមួយខូចថ្លើមប្រមាត់ស្លាប់បាត់បង់ជីវិត ។

Khmer Story Lovers

ក្មៀវតាំងរស់សុទ្ធសឹងជាអ្នកគុននិយម, ស្តាប់ដល់នេះយល់ស្របតាមម្ចាស់កោះឡុងមុនទើបកាត់ច្រើនងក់ក្បាលទទួល ។ តាត្រកូលឡុងបន្ត :

–ប៉ុន្តែសិស្សតាំងប្រាំបីនាក់យល់ឃើញផ្សេងពីគ្នាទៀត ។ មិនតែប៉ុណ្ណោះគេធ្វើឲ្យបងប្អូនខ្ញុំល្វីល្វើទូទៀង ។ យើងទាល់ចំណោះតប់ប្រមល់ក្នុងចិត្តខ្លាំងពេកគិតបោះគម្ពីរនោះចោលឲ្យផុតទុក្ខទៅ ហើយទទួលប្អូនមុំស្នើយោបល់មួយ :

–បើនិយាយពីករិតចេះដឹង, នៅក្នុងលោកយើងនេះមានតែព្រះតេជព្រះគុណមាវធីនៅវត្តសៅលីងជីទេ, យើងគួរទៅរកនិមន្តលោកមកជួយពន្យល់ឬ ?

ខ្ញុំឆ្លើយថា ព្រះតេជព្រះគុណមាវធីបានលាចាកពិភពគុនជាងម្ភៃឆ្នាំហើយ, ក្រែងលោកមិននិមន្តមកតាមយើងឬ ?

ប្អូនមុំឲ្យយោបល់ថា បើដូច្នេះគប្បីចម្លងសេចក្តីក្នុងគម្ពីរនេះបញ្ជូនទៅវត្តសៅលីងជីតែម្តងប្រគេនលោកទតសិន, បើលោកមិនយល់ទេយើងអាចចាត់ទុកគម្ពីរនេះជារបស់ឥតប្រយោជន៍នឹងអាចលែងនឹកនាគតទៅទៀត ។

ខ្ញុំទះដៃផ្តងសរសើរថាយោបល់ល្អណាស់, តែត្រូវចម្លងមួយច្បាប់ទៀតផ្ញើទៅជូនអ្នកសច្ចំយីតាទៅក្អូតាំងផង, ព្រោះអ្នកក្លាហានក្នុងក្រុមធំៗពីរនេះចេះដឹងជ្រៅជ្រះណាស់ ។

យើងខំចម្លងទាំងរូបទាំងអក្សរឥតឲ្យខុសមួយតួឡើយ, រួចចេញដំណើរទៅកាន់វត្តសៅលីងជីមុន ។ ខ្ញុំមិនហ៊ានកុហកអស់លោកទេ, នៅពេលរកគម្ពីរឃើញភ្លាមយើងត្រេកអរសឹងក្លាយជាមនុស្សវិកលចរិត ព្រោះយើងយល់ដោយខ្លួនថា កាលណាហាត់រៀនទ្រឹស្តីក្នុងនោះចប់សព្វគ្រប់យើងនឹងក្លាយជាកំពូលអ្នកគុននិយមក្នុងពិភពលោក ។ យើងមានដឹងឯណាថា ហាត់រៀនយូរកាន់តែខុសច្រើន, ខំស្រាវជ្រាវណាស់តែតែជួបបញ្ហាស្មុគស្មាញណាស់, ព្រោះហេតុនោះទើបយើងលែងទុកជាអាថ៌កំបាំងឬជាសំណាងក្នុងការរកឃើញផែនទីនិងគម្ពីរយុទ្ធសិល្បៈបម្លែក ។

យើងសម្រេចចិត្តថា ទោះដំណឹងនេះលេចឮខ្ចរខ្ចាយដល់ណាក៏យើងមិនសោកស្តាយដែរ, សុំឲ្យតែរកឃើញលោកអ្នកណាយល់អត្ថន័យក្នុងគម្ពីរក៏ជាការបួសនិស្ស័យទៅហើយ ។ យើងទៅដល់វត្តសៅលីងជី បានប្រគេនសេចក្តីចម្លងមួយច្បាប់ទៅសាមណេរក្នុងវត្តយកទៅប្រគេនព្រះតេជព្រះគុណមាវធី ។ សាមណេរអង្គនោះបដិសេធដោយប្រាប់យើងវិញថា ព្រះតេជព្រះគុណមាវធី

ប៉ុន្តែម្ចាស់កោះឡុងមុបន្តទៀតថា:

-ពួកយើងដឹងខ្លួនហាត់រៀនខុសទំនងក៏លែងហ៊ានសាកល្បង បបួលគ្នាពិភាក្សារឿងហ្នឹងឡើងវិញៗ ប្រហែលមកពីយើងល្ងង់ខ្លៅហើយទ្រឹស្តីក្នុងគម្ពីរមានន័យជ្រៅជ្រះពេក ទើបមើលមិនយល់ឬ ? យើងទំស្រាវជ្រាវប៉ុន្មានខែទៀតក៏នៅដោះស្រាយមិនរួច ។

ពេលនោះមាននាវាពួកចោរមួយក្រុមអណ្តែតត្រសែតមកចតកៀនកោះនេះ ។ យើងបបួលគ្នាសម្លាប់មេចោរនិងកូនចោរណាដែលមានកំហុសឬមានទោសអស់មួយចំណែករួចបន្ទុំអ្នក៦ទៀត ឲ្យរស់នៅលើកោះជាមួយយើង ។

បុព្វហេតុនេះគឺមកពីយើងយល់ថា យើងហាត់រៀនយុទ្ធសិល្បៈគ្រប់បែបយ៉ាងច្រើនលើសលុប ហើយទើបបញ្ចូលទ្រឹស្តីចំឡែកនេះថែមទៀតមិនបាន, តោងជ្រើសរើសសិស្សខ្លះទើបមានផ្លូវសង្ឃឹម ៗ. ព្រោះហេតុនេះហើយបានជាយើងជ្រើសរើសអ្នកចេះដឹងជ្រៅជ្រះ ក្នុងចំណោមកូនចោរចំនួនប្រាំមួយនាក់ធ្វើសិស្សតែយើងមិនបង្ហាត់បង្រៀនទេ, យើងបណ្តោយឲ្យគេទៅស្រាវជ្រាវផ្ទាំងផែនទីតាមគំនិតប្រាជ្ញារៀងខ្លួន ។

ប៉ុន្តែគួរចំឡែកណាស់, សិស្សខ្ញុំបីនាក់និងសិស្សប្អូនមុបីនាក់ទៀតសម្ងំស្រាវជ្រាវអស់មួយរយៈពេលមកស្រាប់តែយល់ឃើញប្លែក ៗ ពីគ្នាទៀត ។

យើងពិគ្រោះគ្នាមិនទាន់យល់ថាក្បួនខ្នាតអស់នេះដកស្រង់ពីកំណាព្យបុរាណ របស់កវីនិពន្ធជំនាន់មុននាមលីថៃប៉ាយដ៏ល្បីល្បាញ ។ បងប្អូនយើងពីរនាក់មិនចេះអក្សរសាស្ត្រជ្រៅជ្រះនឹងគេទេ, គប្បីរកអ្នកខ្លាំងពូកែទាំងខាងយុទ្ធសិល្បៈទាំងខាងអក្សរសាស្ត្រទើបមើលយល់ន័យ ។ យើងបបួលគ្នាទៅកាន់ដីគោកស្វែងរកសិស្សពូកែបំណានឲ្យបានបួនរូបរៀងខ្លួន ដោយបានកម្រិតពេលមួយឆ្នាំជួបគ្នាវិញ ។

លោកតាឡុងចង្អុលសិស្សអាវលឿងនិងអាវខៀវដែលឈរក្រោយខ្នងគាត់មួយជួរនោះពោលបន្ត :

– ជំរាបអស់លោកតាមត្រង់ចុះ, សិស្សប៉ុន្មានរូបនេះបើទៅដាក់ពាក្យប្រឡងអក្សរសាស្ត្រនៅរាជធានីច្បាស់ជាបានធ្វើនាម៉ឺនមន្ត្រីធំៗមិនខាន ។ ប៉ុន្តែយើងនាំមកកោះឡុងមុឲ្យហាត់រៀនយុទ្ធសិល្បៈចម្លែកវិញ ។ លុះឃើញផែនទីទើបគេសុខចិត្តរស់នៅជាមួយយើងរហូតដោយម្នាក់ៗយល់ឃើញថារៀនវិជ្ជាយុទ្ធសិល្បៈប្រសើរជាងអក្សរសាស្ត្រ ។

ផែងរវល់ទាក់ទងនឹងរឿងរ៉ាវក្នុងពិភពគុនឃូរឃាណកាស់មកហើយ លោកមិនហ៊ាននាំរឿងនេះទៅពិតទូលលោកបានទេ ។ ទោះបីខ្ញុំនិងប្អូនមុបានខទូចអង្វរយ៉ាងណា ក៏សាមណេរអង្គនេះនៅតែជំទាស់ដាច់ណាត់ ។

ទាល់ចំណោះ ខ្ញុំនិងប្អូនមុក៏បែរមកពិគ្រោះយោបល់គ្នាទៀត ។ ប្អូនមុបានជូនយោបល់ថា ត្រូវប្រើធម៌ក្ដៅបង្ខំឲ្យសាមណេរអង្គនេះជូនទៅជួបព្រះតេជគុណមារវិជី ។ ខ្ញុំគ្រវីក្បាលបញ្ចេញមតិជំទាស់ ដោយពន្យល់ហេតុផលថា: តាំងពីបុរាណកាលមក អ្នកផងតែងចាត់ទុកវត្តសៅលីងជី ជាផ្កាយព្រឹកប្រចាំពិភពគុន ព្រោះឫសគល់នៃយុទ្ធសិល្បៈក្រុមមួយចំនួនធំមានប្រភពចេញពីវត្តនេះ ។ កាលជំនាន់លោកតសីចាំងសានហ្វុង បក្សអ៊ូតាំងដែលបានចាប់កំណើតឡើង ក៏មានប្រភពពីវត្តសៅលីងជីដែរ ហេតុនេះយើងមិនគួរយកបញ្ហានេះទៅប្ដូរនឹងកិត្តិយស កេរ្តិ៍ឈ្មោះរបស់វត្តនេះទេ ។

ពេលនោះប្អូនមុសួរខ្ញុំវិញ :

- អីចឹងតើលោកបងគិតយ៉ាងណាវិញ ?

ខ្ញុំក៏ទាល់គំនិតដែរ មិនដឹងថាត្រូវសម្រេចចិត្តយ៉ាងណាផង ស្រាប់តែពេលនោះមានសាមណេរមួយអង្គទៀតចូលមកដល់ប្រាប់យើងថា ព្រះតេជគុណមារវិជី អនុញ្ញាតឲ្យយើងចូលទៅជួបហើយ ។

ខ្ញុំនិងប្អូនមុ មើលមុខគ្នាឡិងឡង់ ដោយមិននឹកស្មានថា ស្ថានការណ៍ប្រែប្រួលទៅជាយ៉ាងនេះសោះ ។ យើងលបញញឹមដាក់គ្នា ព្រមពេលដែលសាមណេរមកក្រោយនេះបន្លឺឡើង:

- សុំអស់លោកអញ្ជើញតាមអាត្មាមក !

ខ្ញុំញាក់ភ្នែកដាក់ប្អូនមុ , យើងផ្ទើមដំណើរតាមកិតពីក្រោយសាមណេរអង្គនោះ ឆ្ពោះទៅកាន់កុដិធំមួយ ដែលស្ថិតនៅដាច់ពីគេ ។ ពេលទៅដល់ពីមុខទ្វារកុដិ លោកលើកព្រះហស្ថគោះទ្វារបីដង សម្លេងស្អកៗបន្លឺពីខាងក្នុងមក :

- ចូលមក !

យើងនាំគ្នាច្រានទ្វារដើរចូលទៅ ដោយអារម្មណ៍រំភើបញាប់ញ័រ . . . ។

នុះ ! ព្រះតេជគុណមារវិជី មានរាងកាយស្គមស្លេកស្លាំង គង់ព្រះភ្នែកស្ញៀមឥតកម្រើក . . .

ភ្នែកទាំងគូបិទជិត ព្រះហស្តប្រណម្យត្រឹមទ្រូង មាត់ទន្ទេញធម៌រករើបៗ ។ ក្រោយពីធ្វើការវន្ទកិច្ចគោរពព្រះអង្គមក យើងបានបង្ហាញសេចក្តីចម្លងគម្ពីរ និងបញ្ជាក់ពីគោលបំណងរបស់យើងដែលនាំធ្វើដំណើរពីឆ្ងាយ ប្រាប់ព្រះអង្គពេញគ្រប់ ។

ព្រះតេជគុណមារជី ទទួលយកមកពិនិត្យមើលមួយចប់ ស្រាប់តែគ្រវីព្រះកេសហើយជ្រួញចិញ្ចើម ។ លោកមិនអស់ព្រះទ័យ ក៏ចាប់ពិនិត្យសារជាថ្មី ប្រកបដោយព្រះភក្ត្រប្រែប្រួលញឹកញាប់ៗ អស់មួយសន្ទុះធំ , លោកទម្លាក់គម្ពីរចុះ បន្ទូរដង្ហើមលាន់ឮ ហើយមានពុទ្ធដីកាថា :

– មកទល់នឹងចំណាស់នេះហើយ , អាត្មាធ្លាប់បានគម្ពីរក្បួនខ្នាតច្រើនរាប់មិនអស់ មិនដែលប្រទះសេចក្តីនៃគម្ពីរណា ស្មុគស្មាញ ពិបាកយល់ ដូចសេចក្តីនៃគម្ពីរនេះទេ អាត្មាជំរាបដោយត្រង់ថា អាត្មាអស់សមត្ថភាពហើយ ។

គ្រាន់តែឮលោកមានពុទ្ធដីកាដល់ត្រឹមនេះ យើងស្លាក់ថ្លើមក្តុក សេចក្តីសប្បាយក៏រលាយបាត់ទៅវិញភ្លាម យើងក៏ផ្ទឹមផ្ទា ថ្វាយបង្គំលោក ត្រឡប់ចេញមកវិញ ។

បន្ទាប់ពីនោះមក .. យើងក៏នាំគ្នាធ្វើដំណើរ ទៅរកអ្នកសច្ចំ យីតានៅឯភ្នំអ៊ូតាំងទៀត តែគួរឲ្យស្តាយ ដោយយើងទទួលលទ្ធផលមិនខុសពីនៅវត្តសៅលីងជីឡើយ ។ អស់សង្ឃឹមជាខ្លាំង យើងក៏នាំគ្នាវិលមកកោះឡុងមុំវិញទាំងមួហ្មង ដោយតាំងចិត្តថា ពេលទៅដល់ នឹងបោះគម្ពីរនោះចោល ឈប់រវីរវល់សោះនឹងអំពល់ទុក្ខ ។

ប៉ុន្តែ , នៅពេលមកដល់ ស្រាប់តែប្អូនមុមានគំនិតមួយប្លែកទៀត គឺបានស្នើថា គួរយើងអញ្ជើញនាយក្រុមបក្សគ្រប់ក្រុមទាំងអស់ឲ្យមកជួយធ្វើការស្រាវជ្រាវពីគម្ពីរនេះ ដោយរៀបចំជាពិធីជប់លៀង បបរខែកត្តិកឡើង ។ ខ្ញុំសូមបញ្ជាក់ជូនអស់លោកថា បបរនេះធ្វើពីស្មៅពិសេសម៉្យាងឈ្មោះ"ស្មៅផ្តាច់ពោះវៀន រំលាយឆ្អឹង" ជាស្មៅដែលមានផ្កាតែនៅក្នុងខែកត្តិក ក្នុងរវាងដប់ឆ្នាំម្តង ។ ស្មៅនេះមានគុណភាពផ្តល់ឲ្យអ្នកដែលបរិភោគវា នូវកម្លាំងធាតុមួយចំនួន ជាមូលដ្ឋានក្នុងការហាត់យុទ្ធសិល្បៈ ។ គំនិតរបស់យើង , គឺចង់ស្វែងអ្នកខ្លាំងពូកែ ឲ្យមកជួយធ្វើការស្រាវជ្រាវគម្ពីរយុទ្ធសិល្បៈចម្លែកនោះ តាមរយៈការចែកចាយ ផ្លាកបញ្ញា ដែលពួកសេនាយើងបានធ្វើកន្លងមកហើយនោះ ។ យើងមិនយល់សោះថា នៅរាល់លើកដែលយើងធ្វើការអញ្ជើញអស់លោក យើងជួបប្រទះតែរឿងស្មុគស្មាញ ។ ហេតុនេះខ្ញុំជំរាបដោយស្មោះថា : ការដែលខ្ញុំអញ្ជើញ

ឲ្យអ្នកក្លាហានមកកាន់កោះនេះទាំងអស់ដើម្បីលើកដំកើងយុទ្ធសិល្បៈយើងខ្ញុំផ្ទាល់ផង, ដើម្បីលើកដំកើងយុទ្ធសិល្បៈខ្លួនឲ្យល្បួតលាស់ដល់គំរិតផង ។ បើអស់លោកចោទយើងខ្ញុំថាធ្វើបាបអស់លោកនោះជាការមិនពិតទេ ។

ទីងមិនហួសប្អូនធ្វើហ៊ុះៗ:

- សំដីអស់លោកហាក់បង់ក្លួតតុហាកព្ទួកយើងតាំងស្រុងហើយ ។ បើគ្រាន់តែចង់ហៅរកភ្ញៀវជួយស្រាវជ្រាវគម្ពីរចំឡែកឬលើកដំកើងយុទ្ធសិល្បៈផ្ទាល់ខ្លួន ម្តេចអស់លោកសម្លាប់ក្រុមគ្រួសារអ្នកណាដែលគេមិនព្រមមកកោះឡុងមុតាមបញ្ជា ? យើងមិនដែលឮនរណាអញ្ជើញភ្ញៀវរបៀបឃោរឃៅបែបនេះទេ ។

ម្ចាស់កោះងក់ក្បាលហើយទះដៃប្រាសៗ:

- យកបញ្ជីពិភពគុនចេញមក !

ក្រាមនោះមានសិស្សប្រាំបីនាក់ចូលទៅលើកសៀវភៅប្រាំបីដុំចេញមក, ក្នុងមួយដុំៗមានសៀវភៅជាច្រើនក្បាល ។ ម្ចាស់កោះបញ្ជា :

- ចែកបញ្ជីជូនអស់លោកមើលទៅ !

សិស្សទាំងប្រាំបីរូបកាន់សៀវភៅដើរចែកភ្ញៀវមួយក្បាលម្នាក់ តាមក្រុមបក្សរៀងខ្លួន ។ ទីងមិនហួសប្អូនខឡុលសៀវភៅមួយក្បាលមកមើលឃើញមានអក្សរធំៗ លើក្របជាត្រកូលចិននៅស្រុកលីវហឺ !

គាចាស់ភ្ញាក់ព្រើតនឹកថា :

- ស្រុកកំណើតបងប្អូនយើងនៅនោះមែន, តែមិនសូវមាននរណាដឹងទេ ។ កោះឡុងមុ នៅឆ្ងាយដាច់សង្វែង ម៉េចក៏ស្គាល់ច្បាស់លាស់ម៉្លេះ ?

សៀវភៅឯទៀតសុទ្ធតែមានសរសេរអក្សរនៅលើក្របដូចគ្នា ។ តាចិនបើកសៀវភៅគាត់មើលអក្សរខាងក្នុងឃើញមានកត់ត្រាខែឆ្នាំនិងទីកន្លែងដែលគ្រួសារចិនប្រព្រឹត្តអំពើផ្សេងៗក្នុងជីវិត ។

ទីងមិនហួសប្អូន ធ្វើអ្វីនៅកន្លែងណា, ទីងមិនហួសបំពេញអីក្នុងខែណាថ្ងៃណា, ទីងមិនហួសពីរសម្លាប់នរណា.. ទីងមិនហួសប្អូនមើលបណ្តីរបែកញើសច្រោកៗបណ្តីរលបមើលអ្នកដទៃ សុទ្ធតែប្រែទឹកមុខខ្ទៅរែបែកញើសប៉ុនៗគ្រាប់ពោតដែរ ។ មានតែស៊ឺផានម្នាក់គត់ដែលមិនខ្វល់មើលសៀវភៅមានឈ្មោះក្រុមឈានល្មមឹងគេ ។ នាយគិតតែហុតបបរមួយចានហើយមួយចានទៀតធ្វើ

Khmer Story Lovers



ព្រងើយព្រោះមិនចេះអក្សរ ទោះមើលក៏មិនដឹងថាមេចដែរ ។ មួយសន្ទុះក្រោយទើបម្ចាស់កោះ
ស្រែកបញ្ជា:

-ប្រមូលបញ្ជីពិភពគុនទុកវិញ !

សិស្សដែលដើរប្រមូលសៀវភៅតាមបញ្ជា ។ ម្ចាស់កោះពោលទាំងញញឹមថា :

-បងប្អូនខ្ញុំចាត់សេនាទៅស៊ើបដំណឹងមិនមែនចង់ដឹងអាថ៌កំបាំងរបស់អស់លោកទេ គ្រាន់តែក
ទុកចំណាំមើលលេងប៉ុណ្ណោះ ។ ម៉្យាងទៀតក្រុមបក្សដែលត្រូវពួកកោះឡុងមុសម្លាប់សុទ្ធជាជនប្រក
សាហាវយង់ឃ្នងប្រព្រឹត្តអំពើទុច្ចរិតនោះណា ! អស់លោកពិចារណាមើល, ក្រុមបក្សណាខ្លះ ដែល
ត្រូវកោះឡុងមុយើងសម្លាប់ចោល ?

តាចាស់ឈប់ស្ងៀមមួយស្របក់មិនឮនរណាឆ្លើយ ទើបពោលបន្ត :

-កោះឡុងមុកំចាត់ចោលតែជនឧក្រិដ្ឋ, ជនរស់នាំធ្ងន់ផែនដី, នាំឲ្យអ្នកដទៃកើតទុក្ខទោមនស្ស
គឺសុទ្ធជាជនដែលមិនអាចលើកលែងទោសឲ្យបាន ....

ស្រាប់តែប៉ាយជីចាយសួរគាត់ខ្លាំង ៗ :

-ចុះលោកគ្រូប្រដាល់ត្រកូលអ៊ីទៅស្រុកហាំពៃមានប្រព្រឹត្តអំពើឧក្រិដ្ឋអ្វីដែរ បានជាពួកឯងសម្លាប់
គ្រួសារគាត់ចោលតែផុតពូជ ?

ម្ចាស់កោះឡុងមុសើចញញឹមហុតសៀវភៅមួយស្តើងជាងគេក្នុងគំនរបញ្ជីជាច្រើន គ្រវាត់ទៅឲ្យ
ប៉ាយជីចាយព្រមទាំងឆ្លើយ :

- សូមលោកគ្រូពិនិត្យមើល !

សៀវភៅរបូតពីដៃម្ចាស់កោះហោះសន្សឹមៗតម្រង់មុខប៉ាយជីចាយ, ប៉ាយជីចាយលូកដៃវង់ចាំទទួល
តែសៀវភៅនោះហើរមកដល់តុឈប់នឹងក្នុងលំហអាកាសរួចធ្លាក់លើតុចំចានបបរ ។ ប៉ាយជីចាយ
លូកដៃទទួលភ្លាមមិនឲ្យធ្លាក់លើចានចាន់នាំខាសគេ ។ ប៉ុន្តែគាត់កាន់សៀវភៅញ័រដៃទទ្រើ
និកភ័យរន្ធត់ថា :

-គេហាត់រៀនចាល់តែចោលសៀវភៅមកឲ្យយើងបានរបៀបហ្នឹងឃើញថាគេពូកែអស្ចារ្យណាស់,
ប៉ាន់កម្លាំង, ចេះស្ទង់ចម្ងាយ, ចេះលៃឲ្យធ្លាក់សន្សឹមៗ... ប្រហែលស្តៀតចេះស្ទុះឈើសម្លាប់មនុស្ស
ដែលធ្លាប់ឮតែគេនិយាយនោះទេដឹង ? ហេតុអ្វីជនខេះពូកែម៉្លេះ ? បើគប់អាវុធសម្លាត់ពូកែប៉េ

នះដែរ, យើងលែងហ៊ានធ្វើ "លេខមួយ," ហើយ ត្រូវលប់សេចក្តីត្រង់ថា "ចោលអាវុធសម្លាប់ពូកែលេខមួយ" ចេញទៀត !

ប៉ាយដឺតាយមើលសៀវភៅឃើញចំណាំងដែងលើក្របសរសេរថា : គ្រូប្រដាល់ត្រកូលអ៊ីនៅហាំពៃ គាត់បើកមួយសន្លឹកខ្ញាកឃើញអក្សរមួយឃ្លា មានន័យគួរឲ្យស្រៀវស្រើបថា : ថ្ងៃ . . . ខែ . . . ឆ្នាំ...

អ៊ីផុងថាយ បានវ៉ៃលោកតាម្នាក់ ហើយសម្លាប់នាងពោលនៅភូមិហានត្រកូលជី ព្រមទាំងទុកសំបុត្រមួយទម្លាក់ទោសលើក្រុមចោរខ្វាខ្មៅ ។

សន្លឹកមួយទៀតមានសេចក្តីថា :

– ថ្ងៃ . . . ខែ . . . ឆ្នាំ . . . អ៊ីផុកវៃសរកឿងឈ្មោះដាវមួយកូនប្រុសលីវវុនប៉ាំយគេគាល់តែម្នួស ។ ដល់ពេលយប់ស្ងាត់បានចូលទៅសម្លាប់ក្រុមគ្រួសារលីវទាំងដប់បីនាក់បាត់ឥតទ ។

អ៊ីផុងថាយ និងអ៊ីផុងវៃ ជាកូនប្រុសគ្រូប្រដាល់ត្រកូលអ៊ីមានកេរ្តិ៍ឈ្មោះក្នុងពិភពគុនដែរ តែគ្មាននរណាគិតស្មានថា វាបានប្រព្រឹត្តអំពើចោរឃាតយង់ឃ្នងព្រៃផ្សៃយ៉ាងសម្ងាត់ដូច្នេះទេ ។

ប៉ាយដឺតាយ សញ្ជឹងគិតបន្តិចហើយពោល :

– រឿងអស់នេះមិនដឹងពិតឬមិនពិតទេ , ព្រោះមនុស្សស្លាប់អស់ទៅហើយ ។ ខ្ញុំមិនហ៊ានចោទប្រកាន់លោកម្ចាស់កោះឡុងមុនទេ, តែខ្ញុំខ្លាចសេនាអស់លោកចេញទៅប្រតិបត្តិការបានជឿសំដីតក់ដោតគេខ្លះ ១ ណា !

ស្រាប់តែតាំងសានឆ្លើយថា :

– បើលោកគ្រូធំមិនជឿ, សូមមើលកនេះមួយទៀត ។

ពោលហើយគាត់ស្ទុះចូលក្នុងបាត់ចេញមកវិញលើកដៃស្តាំចោលសៀវភៅមួយទៀតស្តើង ឲ្យមើលមែន ។ សៀវភៅនេះហោះកាត់គុលបង្កិចពោះមុខប៉ាយដឺតាយ ហើយធ្លាក់លើតុដូចលើកមុន, ឃើញថា តាំងសានគឺបេះបៀបហុចសៀវភៅដូចម្ចាស់កោះឡុងមុនដែរ ។

មួងនេះប៉ាយដឺតាយប្រឹងខ្លួនចាំទទួលសៀវភៅជាស្រេចទើបគាត់បើកមើលខាងក្រោមស្គាល់ ច្បាស់ជាបញ្ជីចំណូលចំណាយរបស់គ្រួសារត្រកូលអ៊ី ។

កាលនៅក្មេងប៉ាយដឺតាយរកប់រកគ្រូប្រដាល់ត្រកូលអ៊ីយ៉ាងស្និទ្ធស្នាល ។ គាត់ស្គាល់អក្សរលោកគ្រូអ៊ីហ្វូតទល់ស្ទាវ, ឯអក្សរក្នុងបញ្ជីពិតជាអក្សរគាត់មែន ។ មានកត់ត្រាគ្រប់ចំណូលចំណាយនិង

បំណុលតិចច្រើន, កន្លែងខ្លះមានសរសេរអក្សរក្រហមថា "ត្រូវតែសម្លាប់ចោល" ផង ។ ដូចជា សន្លឹកមួយនោះប៉ាយដឺចាយឃើញកត់ថា ថ្ងៃ... ខែ... បានទិញដីស្រែតាចូវប៉ែតសិបហិកតារតម្លៃចិត សិបតម៉ឺន ។

ប៉ាយដឺចាយនឹកថា ប្រាក់ប៉ែតសិបតម៉ឺនយកទិញដីស្រែប៉ែតសិបហិកតាដូចជា « តា-ក » គេ បោកហើយ, ច្បាស់ជាមានការប្រព្រឹត្តបោកប្រាស់ពិតប្រាកដណាស់ ។

ប៉ាយដឺចាយបើកមើលគ្រប់ទំព័រមានចារអក្សរក្រហមថាគួរសម្លាប់នោះ មានន័យថា : ថ្ងៃ... ខែ... : បានទទួលប្រាក់ពីលោកមេស្រុកចាន់ចំនួនពីរពាន់ប្រាំរយតម៉ឺន, គាត់នឹកថាអាល័យយើងជាអ្នកគុណ និយមសុចរិតត្រឹមត្រូវម៉េចហ៊ានទទួលប្រាក់ពីលោកមេស្រុក ? ពិតជាពិះជាទំព្រ្តប្រមូលលុយកាក់មក ចែកចាយគ្នាហើយ ។

ប៉ាយដឺចាយបើកមើលបន្តបន្ទាប់គាត់ឃើញចំណារថាត្រូវសម្លាប់ចោលប្រហែលហុកសិប គាត់ ដឹងថាអក្សរក្រហមពិតជាចាន់សាននិងលីសៃកត់ចំណាំពីអំពើឧក្រិដ្ឋដែលត្រូវប្រហារជីវិតហើយ ។

គាត់ផុកដង្ហើមធំបិទសៀវភៅទុកហើយពោលទាំងសោកសៅថា:

— ហ៊ី ! ស្គាល់មនុស្សតែមិនស្គាល់ចិត្តសោះ ! អាល័យអ្នកនេះត្រូវស្លាប់មែន, បើយើងឃើញបញ្ជីនេះ មុនក៏យើងសម្លាប់ឥតយោគយល់មិត្តដែរ, កោះឡុងមុកត់ខុន យើងប៉ាយដឺចាយត្រូវសម្លាប់ឲ្យផុតពូជ !

ពោលហើយគាត់ក្រោកក្រេះដើរទៅរកចាន់សានហុចសៀវភៅសងវិញ ព្រមទាំងពោលដោយ ស្មោះថា: « អស្ចារ្យមែន ! ពូកែមែន ! ខ្ញុំសុំសរសើរ ! » ។

(នៅមានត)

ដំកល់ទុកតាមលេខ ៤២១ ចុះថ្ងៃទី ២៣-៦-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers